**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសុខាភិបាល

# សេចក្តីជូនព័ត៌មានរបស់ក្រសួងសុខាភិបាល
# ស្តីពី
# ការរកឃើញការកើនឡើងនៃជំងឺពងបែកដៃជើងនិងមាត់នៅរដូវក្តៅនេះ
# និងវិធានការបង្ការជំងឺ

ក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សូមជម្រាបជូនសាធារណៈជនជ្រាបថា ក្រសួងសុខាភិបាល បានរកឃើញការកើនឡើងនៃករណីជំងឺពងបែកដៃជើងនិងមាត់ នៅលើកុមារអាយុក្រោម៥ឆ្នាំ និងករណីខ្លះមានសភាពធ្ងន់ធ្ងរដែលតម្រូវសំរាកនៅមន្ទីរពេទ្យកុមារដើម្បីសង្គ្រោះបន្ទាន់ នៅក្នុងអំឡុងពេលនៃការកើនឡើងកំដៅនេះ ។

ជំងឺពងបែកដៃ ជើង និងមាត់ គឺជាជំងឺឆ្លងមួយប្រភេទកើតឡើង ញឹកញាប់ ចំពោះទារក និង កុមារ។ វាបង្កអោយមានរោគសញ្ញា គ្រុនក្តៅ មានដំបៅឈឺក្នុងមាត់ និង មានពងកន្ទួល លើបាតដៃ បាតជើង និង កំប៉េះគូទ។ វាកើតមាននៅក្នុងប្រទេសជាច្រើនពេញទូទាំងពិភពលោក។ ជំងឺពងបែក ដៃជើង និងមាត់ ភាគច្រើនជាជំងឺស្រាល ហើយអ្នកជំងឺ ស្ទើរតែទាំងអស់ជាសះស្បើយក្នុងរយៈពី ៧ថ្ងៃ ទៅ១០ ថ្ងៃ ដោយពុំចាំបាច់មានការព្យាបាល ហើយកម្រមានផលវិបាកណាស់ អ្នកជំងឺត្រូវបរិភោគទឹកអោយបានច្រើន ហើយអ្នកជំងឺអាចត្រូវការ ថ្នាំបញ្ចុះកំដៅ និងថ្នាំបំបាត់ការឈឺចាប់ ដែលបណ្តាលមកពីពងបែកក្នុងមាត់។ មិនត្រូវប្រើថ្នាំ អាស្ពីរីន (aspirin) ដើម្បីបញ្ចុះកំដៅឡើយ។

ជាកម្រ ជំងឺពងបែក ដៃ ជើង និងមាត់ អាចបង្កឲ្យមានផលវិបាកធ្ងន់ធ្ងរមួយចំនួន រួមមាន រោគសញ្ញាប្រព័ន្ធប្រសាទ (សន្លឹម ប្រកាច់ ឬ កន្ទ្រាក់ដៃជើង) និងរោគសញ្ញាផ្លូវដង្ហើម (ហត់)។ អ្នកជំងឺដែលមានផលវិបាក ធ្ងន់ធ្ងរ ត្រូវ ប្រញាប់ទៅមន្ទីរពេទ្យដែលនៅជិតបំផុត ។ ជំងឺពងបែក ដៃ ជើង និងមាត់ អាចឆ្លង ពីមនុស្សម្នាក់ទៅ មនុស្សម្នាក់ទៀត ដោយការប៉ះពាល់ផ្ទាល់ជាមួយនឹងវត្ថុរាវ នៃផ្លូវដង្ហើម (ទឹកមាត់ កំហាក និងសំបោរ) ទឹករងៃ ដែលចេញពីពងបែក លាមក នៃអ្នកជំងឺ។ អ្នកជំងឺអាចចំលង ខ្លាំងបំផុតក្នុងសប្តាហ៍ទីមួយ។ ជំងឺពងបែក ដៃ ជើង និងមាត់ មិនឆ្លងពីមនុស្សទៅសត្វឬពីសត្វមកមនុស្សឡើយ។

បងប្អូនអាចការពារបានការឆ្លងជំងឺនេះ ដោយការអនុវត្ត អនាម័យល្អ និងការយកកូនទៅពេទ្យទាន់ពេល ប្រសិនបើមានរោគសញ្ញាធ្ងន់ធ្ងរ។ អ្នកត្រូវលាងដៃកុមារអោយបានញឹកញាប់ជាមួយទឹកនិងសាប៊ូ ឬជាមួយទឹកអាល់កុល ជាពិសេសក្រោយប៉ះពងបែក ឬ ដំបៅ មុនពេលរៀបចំអាហារ មុនពេលបរិភោគ មុនបញ្ចុក ចំណីដល់ទារក ឬ កុមារ ក្រោយប្រើប្រាស់បង្គន់អនាម័យ និងក្រោយប្តូរទ្រនាប់ គូទទារក ឬជូតសំអាតរាងកាយកុមារ។ លាងសំអាតផ្ទៃនិង របស់ដែលប្រលាក់ដោយទឹកនិងសាប៊ូ។ ជៀសវាងការប៉ះពាល់ស្និទ្ធស្នាល (ថើប អោប ប្រើប្រាស់សម្ភារសំរាប់ហូបចុក រួមគ្នា។ល។) ជាមួយក្មេងដែលមានជំងឺពងបែក ដៃ ជើង និងមាត់ អាចកាត់បន្ថយការឆ្លងផងដែរ។

ផ្តល់អាហារដែលមានជីវជាតិច្រើន និងទឹកស្អាតដល់កុមារ។ប្រើស្ពាបព្រា និងចានដាច់ដោយឡែក សំរាប់កុមារនីមួយៗ។



ទីស្តីការក្រសួងសុខាភិបាល ផ្លូវលេខ ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) [illegible]

**ឯកឧត្តមសាស្ត្រាចារ្យ ម៉ម ប៊ុនហេង** រដ្ឋមន្ត្រីក្រសួងសុខាភិបាល មានប្រសាសន៍ថា " *គ្រប់ៗគ្នា ត្រូវតែមានការប្រុងប្រយ័ត្នខ្ពស់ចំពោះជំងឺពងបែក ដៃ ជើង និងមាត់ នៅពេលដែលអាកាសធាតុក្តៅ ឡើងក្តៅខ្លាំងនេះ តាមរយៈការរក្សាអនាម័យឲ្យបានល្អ ឧស្សាហ៍លាងដៃជាមួយសាប៊ូនិងទឹកឲ្យបានញឹកញាប់ ទាំងកុមារនិងអ្នកថែទាំកុមារ ។ បើកុមារឬទារកមានសញ្ញាគ្រោះថ្នាក់ដូចជា សន្លឹម ប្រកាច់ ឬ ក្រន្ទាក់ដៃជើង ឬរោគសញ្ញាផ្លូវដង្ហើម (ហត់) ត្រូវប្រញាប់បញ្ជូនទៅមន្ទីរពេទ្យដែលនៅជិតបំផុត ។* "

ក្រសួងសុខាភិបាលសូមលើកទឹកចិត្តឲ្យសាធារណជនទូទៅអនុវត្តតាមដំបូន្មានសាមញ្ញខាងលើ ដើម្បីការពារកុមារ និងក្រុមគ្រួសារ និងសូមជូនពរអ្នកទាំងអស់គ្នាជួបនូវសុខភាពល្អ ។

ក្រសួងសុខាភិបាល និងបន្តធ្វើការជូនដំណឹងដល់សាធារណជន អំពីការវិវត្តនៃបញ្ហាសុខភាពតាមគេហទំព័ររបស់នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង www.cdcmoh.gov.kh និងហ្វេសប៊ុកឈ្មោះ នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លងនៃក្រសួងសុខាភិបាល។

សំរាប់ព័ត៌មានបន្ថែម៖ សូមទាក់ទងលេខទូរស័ព្ទទាន់ហេតុការណ៍ដោយឥតគិតថ្លៃ 115 ទោះគ្មានឥណទានក្នុងទូរស័ព្ទរបស់អ្នកក៏អាចទូរស័ព្ទចូលបានដែរ ឬទំនាក់ទំនង៖ ក្រសួងសុខាភិបាល

លោកវេជ្ជបណ្ឌិត លី សូវ៉ាន់ ៖ ០១២ ៨២៥ ៤២៤

ថ្ងៃសុក្រ ២ រោច ខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ពស ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៩







ទីស្តីការក្រសួងសុខាភិបាល ផ្លូវលេខ ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩